# ជំពូកទី០៧
# ផែនការគ្រប់គ្រងបរិស្ថាន

Draft

## ៧.១. សេចក្តីផ្តើម

ជំពូកមុនបានលើកឡើងលំអិតអំពីសក្តានុពលនៃការប៉ះពាល់បរិស្ថាន-សង្គមរបស់គំរោង និងវិធានការកាត់បន្ថយផ្សេងៗ។ ជំពូកនេះនឹងបង្ហាញអំពីផែនការគ្រប់គ្រងបរិស្ថាន-សង្គម យុទ្ធសាស្ត្របន្ថែម និងវិធីសាស្ត្រគ្រប់គ្រងមួយចំនួន សំរាប់អង្កេតតាមដានពីប្រសិទ្ធិភាពនៃវិធានការទាំងនោះ។ ប្រសិនបើវិធានការគ្រប់គ្រងបរិស្ថាន-សង្គមមិនបានបញ្ចូលទៅក្នុងការរៀបចំគំរោងលំអិត និងកិច្ចសន្យាផ្សេងៗទាក់ទងនឹងការងារដែលបានស្នើឡើងនោះទេ ការប៉ះពាល់បរិស្ថាន-សង្គមអវិជ្ជមាន នឹងកើតមានឡើងដោយប្រការណាមួយជាពុំខាន។ ការអនុវត្តដ៏មានប្រសិទ្ធិភាពជាការចាំបាច់ ដើម្បីធានាថា គំរោងនឹងមានការប៉ះពាល់ជាអវិជ្ជមានក្នុងកំរិតអប្បបរមាទៅលើបរិស្ថានជីវសាស្ត្រ រូបសាស្ត្រ និងសេដ្ឋកិច្ច-សង្គម។ ការងារនេះអាចសំរេចបានដោយការរៀបចំ និងគោរពតាមផែនការគ្រប់គ្រងបរិស្ថាន-សង្គមលំអិត កម្មវិធីបណ្តុះបណ្តាល និងអង្កេតតាមដាននៅក្នុងដំណាក់កាលមុនប្រតិបត្តិ ប្រតិបត្តិ និងបញ្ចប់គំរោង។

## ៧.២. ការសង្ខេបពីហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ

យោងតាមលទ្ធផលនៃការសិក្សាការវាយតំលៃហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងសង្គម ដែលបង្កឡើងដោយសារសកម្មភាពនៅគ្រប់ដំណាក់កាលមុនប្រតិបត្តិគំរោង ប្រតិបត្តិគំរោង និងបញ្ចប់គំរោង ម្ចាស់គំរោងនឹងត្រូវរៀបចំ និងកំណត់នូវវិធានការសំខាន់ៗមួយចំនួនសំរាប់ធ្វើការទប់ស្កាត់ និងកាត់បន្ថយនូវរាល់បណ្តាហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដើម្បីធានាបានការគ្រប់គ្រងធនធានបរិស្ថានតំបន់នោះប្រកបដោយប្រសិទ្ធភាពស្របតាមបច្ចេកទេស និងបទដ្ឋានបរិស្ថាន (ខ្លឹមសារហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយលំអិតដូចមានបង្ហាញនៅក្នុងជំពូកទី៦)។

ក្នុងការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាននេះឱ្យបានដល់កំរិតអប្បបរមា នោះម្ចាស់គម្រោងត្រូវមានវិធានការ និងត្រូវអនុវត្តនូវសកម្មភាពមួយចំនួនដូចជា:

**ដំណាក់កាលមុនប្រតិបត្តិគំរោង**

| ការប៉ះពាល់អវិជ្ជមាន | វិធានការកាត់បន្ថយ |
|---|---|
| • ការបាត់បង់ព្រៃឈើប្រមាណ 44 ហ.តដោយសារការឈូសសំអាតព្រៃសំរាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធគំរោង<br>• ការប៉ះពាល់ដោយផ្ទាល់ និងប្រយោលដល់សត្វព្រៃ ដោយសារការបរបាញ់ពីសំណាកបុគ្គលិក-កម្មករគំរោង និងការរំខានពីសកម្មភាពសាងសង់<br>• ការធ្វើឱ្យខូចខាតប្រព័ន្ធផ្លូវទឹក និងគុណភាពទឹក ដោយសារការហូរច្រោះអាចម៍ដី និងការទុកដាក់សំណល់គ្រប់ប្រភេទ | • ចៀសវាងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងព្រៃទ្រនាប់តាមដងអូរ<br>• ផ្សព្វផ្សាយ និងអប់រំដល់បុគ្គលិកកម្មករឱ្យយល់ដឹងពីសារៈសំខាន់នៃព្រៃឈើ និងសត្វព្រៃ ព្រមទាំងហាមឃាត់ដាច់ខាតមិនឱ្យបុគ្គលិក-កម្មករមានការពាក់ព័ន្ធនឹងការបំផ្លិចបំផ្លាញធនធានទាំងនេះ<br>• ផ្សព្វផ្សាយ និងអប់រំណែនាំឱ្យបុគ្គលិក-កម្មករយល់ដឹងអំពី |

មិនបានត្រឹមត្រូវ

- ការប៉ះពាល់ដល់ការប្រើប្រាស់ដី ដោយសារភាពជាន់គ្នារវាងទីតាំង គំរោង និងដីស្រែ-ចំការរបស់ប្រជាពលរដ្ឋ
- ការប៉ះពាល់ដល់មុខរបរ ការរកអនុផល និងការចិញ្ចឹមសត្វរបស់ប្រជាពលរដ្ឋ
- ការប៉ះពាល់ដល់ប្រពៃណីវប្បធម៌ជនជាតិដើមភាគតិចទំពួន និង ចារាយ ដោយសារលំហូរចូលនៃប្រពៃណី-វប្បធម៌ខាងក្រៅ

គោលការណ៍ណែនាំបច្ចេកទេសនៃការទុកដាក់សំណល់គ្រប់ប្រភេទឱ្យមានសុវត្ថិភាព

- ធ្វើការដោះស្រាយការប៉ះពាល់ដីស្រែ-ចំការ តាមរយៈការធ្វើសំណង/ប៉ះប៉ូវ ជាថវិកា ដោយផ្អែកទៅតាមប្រភេទដំណាំ និងទិន្នផលទទួលបានក្នុងមួយ ឆ្នាំៗ និងប៉ះប៉ូវជាថវិការសំរាប់កំលាំងពលកម្មចំពោះស្រែ-ចំការពនេតចរ
- អនុគ្រោះឱ្យប្រជាពលរដ្ឋចូលប្រកបរបររកអនុផលព្រៃឈើនៅក្នុងទីតាំង គំរោង និងផ្សព្វផ្សាយឱ្យបុគ្គលិក-កម្មករចេះជួយថែរក្សាប្រពៃណី-វប្បធម៌ របស់ប្រជាពលរដ្ឋទាំងអស់

**ដំណាក់កាលប្រតិបត្តិគំរោង**

**ការប៉ះពាល់អវិជ្ជមាន**

- ការបាត់បង់ព្រៃឈើប្រមាណ 260ហ.ត. ដោយសារការធ្វើអាជីវកម្មរ៉ែ
- ការបាត់បង់សត្វព្រៃ ដោយសារការបាត់បង់ទីជំរក ការបរបាញ់ពីសំណាក់បុគ្គលិក-កម្មករគំរោង និងការរំខានពីសកម្មភាពអាជីវកម្ម
- ការធ្វើឱ្យខូចខាតរចនាសម្ព័ន្ធ និងគុណភាពដី ដោយសារការហូរច្រោះ/ការ កាយដីស្រទាប់លើ និងការបាត់បង់ជីជាតិដី
- ការធ្វើឱ្យខូចខាតគុណភាពទឹកដោយសារការហូរច្រោះអាចម៍ដី និងសារធាតុគ្រោះថ្នាក់ចូលទៅក្នុងប្រព័ន្ធផ្លូវទឹក និងការទុកដាក់សំណល់មិន បានត្រឹមត្រូវ
- ការធ្វើឱ្យប៉ះពាល់ដល់នៃការប្រើប្រាស់ទឹកអូររបស់ប្រជា-ពលរដ្ឋ
- ការប៉ះពាល់ដល់ការប្រើប្រាស់ដី ដោយសារភាពជាន់គ្នារវាងទីតាំងគំរោង និងដីស្រែ-ចំការរបស់ប្រជាពលរដ្ឋ
- ការបាត់បង់មុខរបររបស់ប្រជាពលរដ្ឋ ដោយសារការបាត់

**វិធានការកាត់បន្ថយ**

- ចៀសវាងការធ្វើអាជីវកម្មនៅលើដីព្រៃទ្រនាប់តាមដងអូរ និងធ្វើការឈូសឆាយទៅតាមផែនការមេ
- ផ្សព្វផ្សាយ និងអប់រំដល់បុគ្គលិកកម្មករឱ្យយល់ដឹងពីសារៈសំខាន់នៃព្រៃឈើ និងសត្វព្រៃ ព្រមទាំងហាមឃាត់ដាច់ខាតមិនឱ្យបុគ្គលិក-កម្មករមានការពាក់ព័ន្ធនឹងការបំផ្លិចបំផ្លាញធនធាននេះ
- ផ្សព្វផ្សាយ និងអប់រំណែនាំឱ្យបុគ្គលិក-កម្មករយល់ដឹងអំពីគោលការណ៍ណែនាំបច្ចេកទេសនៃការទុកដាក់ និងប្រើប្រាស់សារធាតុគ្រោះថ្នាក់ និងការទុកដាក់សំណល់គ្រប់ប្រភេទឱ្យមានសុវត្ថិភាព
- ធ្វើការដោះស្រាយការប៉ះពាល់ដីស្រែ-ចំការ តាមរយៈការធ្វើសំណង/ប៉ះប៉ូវជាថវិកា ដោយផ្អែកទៅតាមប្រភេទដំណាំ និងទិន្នផលទទួលបានក្នុងមួយឆ្នាំៗ និងប៉ះប៉ូវជាថវិការសំរាប់កំលាំងពលកម្មចំពោះស្រែ-ចំការពនេតចរ
- រៀបចំកម្មវិធីធ្វើអនាម័យបរិស្ថាននៅក្នុងបរិវេណទីស្នាក់ការ/ជំរុំស្នាក់នៅ

Draft

បង់ព្រៃឈើ ដែលជា ប្រភពផ្តល់នូវអុស អនុផលព្រៃឈើ និងចំណើសំរាប់ការចិញ្ចឹមសត្វ

**ដំណាក់កាលបញ្ចប់ប្រតិបត្តិតំរោង**

**ការប៉ះពាល់អវិជ្ជមាន**

- ការបន្សល់ទុកនូវរណ្តៅរ៉ែ និងសសរអណ្តូងជាដើម
- ការបន្សល់ទុកនូវសំណល់នានា
- ការបន្សល់ទុកនូវហេដ្ឋារចនាសម្ព័ន្ធ ( ឧ. អាគារ ជំរុំ រោងជាង រោងចក្រ ប្រព័ន្ធលូទឹកជាដើម
- ការតាំងអាណាគមន៍របស់ពពួកសត្វ និងរុក្ខជាតិនានានៅក្នុងទីតាំងតំរោង
- សក្តានុពលនូវការលេចចេញវត្តមានពពួកសត្វ និងរុក្ខជាតិថ្មីៗ
- អាចបង្កឱ្យមានបញ្ហាដល់ការបំលាស់ទីរបស់សត្វព្រៃ ដោយសារវត្តមានរណ្តៅរ៉ែ និងសសរអណ្តូងជាដើម
- ការប៉ះពាល់ដល់សុខភាព និងសុខមាលភាពសាធារណៈ
- អាចបាត់បង់ឱកាសការងាររបស់ប្រជាពលរដ្ឋមូលដ្ឋាន

**វិធានការកាត់បន្ថយ**

- តំរោងនឹងធ្វើការលុបរណ្តៅរ៉ែដែលបានជីក និងចំរាញ់យករ៉ែរួចមកចាក់នៅក្នុងរណ្តៅដើមវិញ
- តំរោងនឹងអប់រំណែនាំដល់បុគ្គលិក-កម្មករឱ្យបះល់ដឹង និងអនុវត្តន៍គោលការណ៍ណែនាំក្នុងការទុកដាក់សំណល់គ្រប់ប្រភេទឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
- តំរោងនឹងធ្វើការរើចេញនូវហេដ្ឋារចនាសម្ព័ន្ធតំរោងឱ្យបានមុនពេលបញ្ចប់តំរោងជាស្ថាពរ
- តំរោងនឹងធ្វើការការដាំដើមឈើឡើងវិញ
- តំរោងនឹងផ្សព្វផ្សាយ និងអប់រំសហគមន៍មូលដ្ឋានឱ្យយល់ដឹងអំពី Sustainability Program ដើម្បីឱ្យសហគមន៍មានសមត្ថភាពក្នុងការចិញ្ចឹមជីវិតរបស់ពួកគាត់បាននៅពេលដែលបាត់បង់ឱកាសការងារ
- តំរោងនឹងរៀបចំ និងអនុវត្តន៍ផែនការបិទតំរោងទៅតាមគោលការណ៍ណែនាំបច្ចេកទេស និងផែនការគ្រប់គ្រងបរិស្ថាន ( **ជំពូកទី**07 )

Draft

### ៧.៣ - កម្មវិធីបណ្តុះបណ្តាល

ការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីឱ្យយល់ដឹងពីបញ្ហាបរិស្ថានជាផ្នែកមួយក្នុងផែនការគ្រប់គ្រងបរិស្ថាន ដើម្បីឱ្យប្រជាពលរដ្ឋចូលរួមចំណែកក្នុងការជួយការពារការបំពុលបរិស្ថាន ពេលតំរោងចាប់ផ្តើមអនុវត្ត ពិសេសការឈូសឆាយដី ការបញ្ចេញសំណល់រឹង-រាវ ( ជាពិសេសការបង្ហូរសំណល់ប្រេង) និងសុវត្ថិភាពការងារ ។ ដូច្នេះ ម្ចាស់តំរោងត្រូវមានកម្មវិធីបំពាក់បំប៉នចំពោះបុគ្គលិក-កម្មកររបស់ខ្លួនឱ្យយល់ដឹងពីបញ្ហាបំពុលបរិស្ថាន និងការថែរក្សាសោភ័ណ្ឌភាពបរិស្ថាន។ រាល់ការបំពាក់បំប៉នទាំងនេះ គឺក្រុមហ៊ុនជាអ្នកចំណាយទាំងស្រុង ។ ការបណ្តុះបណ្តាលនេះមានដូចជា:

- ផ្តល់ចំណេះដឹងបច្ចេកទេសសំរាប់ប្រើ ឬបញ្ហាគ្រឿងយន្តពេលដំណើរការអាជីវកម្ម ។

- ផ្តល់ចំណេះដឹងសំរាប់បើកបរយានយន្តធុនធំ និងគ្រឿងចក្រគ្រប់ប្រភេទប្រកបដោយការទទួលខុសត្រូវ ។
- ផ្តល់ចំណេះដឹងពីការការពារសុវត្ថិភាពការងារ និងវិធីសាស្ត្រការពារសុខភាពផ្ទាល់ខ្លួន ពីជំងឺនានា ។
- អប់រំឱ្យចេះពីការបំពាក់ឧបករណ៍ការពារខ្លួនក្នុងពេលធ្វើការ ។
- ការអប់រំចំពោះការគ្រប់គ្រងសំណល់រឹង-រាវ គឺតម្រូវឱ្យមានការយកចិត្តទុកដាក់លើការបង្ហូរសំណល់ប្រេង ការបោះចោលសំណល់អាហារ ថង់ផ្លាស្ទិច សម្ភារៈខូច ឬរបស់ដែលមិនប្រើប្រាស់ ចូលទៅក្នុងទឹកអូរ ។
- អប់រំឱ្យយល់ដឹងពីអត្ថប្រយោជន៍នៃធនធានបរិស្ថានសំខាន់ៗ ដែលមាននៅក្នុងតំបន់គំរោង សំរាប់តំរូវការរបស់សង្គម និងជីវភាពប្រចាំថ្ងៃដូចជាទឹក ព្រៃឈើ និងសត្វព្រៃ ។ ស្របពេលជាមួយគ្នានោះដែរ ម្ចាស់គំរោងត្រូវរៀបចំ និងផ្សព្វផ្សាយអំពីបទបញ្ជា និងពិន័យនានាដែលពាក់ព័ន្ធនឹងការបរបាញ់សត្វព្រៃ និងកាប់ឈើ ។

## ៧.៤ កម្មវិធីត្រួតពិនិត្យបរិស្ថាន

កម្មវិធីត្រួតពិនិត្យបរិស្ថាន Environmental Monitoring Programme គឺជាកម្មវិធីមួយដែលម្ចាស់ ក្រុមហ៊ុនត្រូវធ្វើការត្រួតពិនិត្យដោយខ្លួនឯងនៅគ្រប់វដ្តជីវិតរបស់គំរោង ដើម្បីចូលរួមកាត់បន្ថយនូវហេតុប៉ះពាល់ ដែលអាចកើតមានឡើងក្នុងការចូលរួមចំណែកការថែរក្សានូវធនធានបរិស្ថាន ក៏ដូចជាការអនុវត្តន៍នូវកិច្ចដំណើរការគំរោងឱ្យមានស្ថេរភាព។ ការត្រួតពិនិត្យបរិស្ថានត្រូវមានវិធីសាស្ត្រ ស្ថាប័នទទួលខុសត្រូវ វដ្តនៃការត្រួតពិនិត្យបរិស្ថាន ហើយក្រុមហ៊ុនត្រូវរាយការណ៍ត្រួតពិនិត្យបរិស្ថានជូនក្រសួងបរិស្ថាន (នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន) រៀងរាល់០៦ ខែម្តង ។

### ៧.៤.១ វិធីសាស្ត្រនៃការត្រួតពិនិត្យផែនការគ្រប់គ្រងបរិស្ថាន

វិធីសាស្ត្រក្នុងការត្រួតពិនិត្យបរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថាន គឺជាឯកសារមួយដែលពិពណ៌នាអំពី:

- វិធីសាស្ត្រនៃការគ្រប់គ្រង និងកាត់បន្ថយសក្តានុពលនៃការប៉ះពាល់បរិស្ថាន-សង្គម ដោយមានគោលបំណងសកម្មភាព និងភារកិច្ចច្បាស់លាស់ ។
- ថាតើសកម្មភាព និងភារកិច្ចខាងលើត្រូវអនុវត្តន៍យ៉ាងណា? (តើអ្នកណាជាអ្នកទទួលខុសត្រូវ? តើធ្វើនៅពេលណា? តើធ្វើនៅកន្លែងណា? ជាដើម) ។
- ថាតើការអនុវត្តសកម្មភាព និងភារកិច្ចខាងលើ ត្រូវបានអង្កេតតាមដាន និងត្រួតពិនិត្យបែបណា ដើម្បីធានាបានថាសកម្មភាព និងភារកិច្ចទាំងនោះត្រូវបានយកមកអនុវត្តន៍ដោយមានប្រសិទ្ធិភាព ហើយសំរេចតាមគោលបំណងដែលបានកំណត់ ។

ក្នុងន័យនេះ ផែនការគ្រប់គ្រងបរិស្ថាន-សង្គមសំរាប់គំរោងអភិវឌ្ឍន៍ធ្វើអាជីវកម្មរ៉ែដែកនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណង ដើម្បីផ្តល់ជាចក្ខុវិស័យសំរាប់ការអនុវត្តផែនការកាត់បន្ថយ កម្មវិធីបណ្តុះបណ្តាលអង្កេតតាមដាន និងត្រួតពិនិត្យនៅក្នុងដំណាក់កាលមុនប្រតិបត្តិ ប្រតិបត្តិ និងបញ្ចប់គំរោង ដើម្បីធានាឱ្យបាននូវការកាត់បន្ថយសក្តានុពលនៃ ការប៉ះពាល់បរិស្ថានអវិជ្ជមានឱ្យដល់កំរិតអប្បបរមា ។

Draft

### ៧.៤.២ ស្ថាប័នទទួលខុសត្រូវក្នុងការអង្កេតតាមដាន និងត្រួតពិនិត្យបរិស្ថាន

រាល់កម្មវិធីអង្កេតតាមដាន និងត្រួតពិនិត្យបរិស្ថាន ដូចមានរាប់រាប់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាននឹងត្រូវធ្វើឡើងដោយក្រុមហ៊ុន និងអ្នកម៉ៅការផ្ទាល់។ ដោយឡែក ក្រសួងបរិស្ថាន (នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន) ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធនានានឹងចុះធ្វើការអង្កេតតាមដាន ត្រួតពិនិត្យ និងការអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថានព្រមទាំងធ្វើការផ្ទៀងផ្ទាត់លើរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់ក្រុមហ៊ុន ក្នុងកំឡុងពេល **០៦ខែ/ដង**។ ក្នុងន័យនេះក្រុមហ៊ុននឹងស្វាគមន៍ និងសហការល្អជាមួយនឹងក្រុមការងារចុះអង្កេតតាមដានក្នុងការបំពេញការងារនេះ។

### ៧.៤.៣ របាយការណ៍ត្រួតពិនិត្យបរិស្ថាន

ការរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន គឺជាវិធីសាស្ត្រដ៏សំខាន់ដែលអាចផ្តល់ព័ត៌មានដល់អ្នកគ្រប់គ្រង ដើម្បីធ្វើការកែលំអការអនុវត្តន៍។ ដើម្បីធានាថាស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងបរិស្ថាន (នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន) ទទួលបានព័ត៌មានអំពីលទ្ធផលនៃការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់ក្រុមហ៊ុន Hoang Anh Rattanakiri Co., Ltd. របាយការណ៍ប្រចាំឆមាសនឹងត្រូវបានរៀបចំឡើងទៅតាមដំណាក់កាលនីមួយៗនៃសកម្មភាពគំរោង។ ក្នុងន័យនេះ ក្រុមហ៊ុននឹងចាត់តាំងអ្នកទទួលខុសត្រូវក្នុងការត្រួត-ពិនិត្យការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងរៀបចំរបាយការណ៍អំពីការអនុវត្តនេះមកក្រសួងបរិស្ថាន (នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន) ក្នុងកំឡុងពេល **០៦ខែ/ដង**។

ជាមួយគ្នានេះ ក្រសួងបរិស្ថាន (នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន) ជាអ្នកទទួលនូវរាល់របាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន។ ប្រសិនបើរបាយការណ៍បង្ហាញឱ្យឃើញនូវចំណុចខ្វះខាតណាមួយទាក់ទងនឹងការអនុវត្តផែនការគ្រប់គ្រងបរិស្ថានក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គំរោង នោះក្រសួងនឹងធ្វើការជូនដំណឹងអំពីចំណុចខ្វះខាតទាំងនេះទៅក្រុមហ៊ុន ដើម្បីឱ្យធ្វើការកែប្រែចំណុចចាំបាច់ណាមួយ រួចធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងបរិស្ថាន ដើម្បីឱ្យឆ្លើយតបទៅនឹងការកែប្រែនេះ។

### ៧.៤.៤ កម្មវិធី និងខួបនៃការត្រួតពិនិត្យបរិស្ថាន

កម្មវិធីត្រួតពិនិត្យបរិស្ថានត្រូវធ្វើឡើងនៅក្នុង ០៣ ដំណាក់កាលដូចខាងក្រោម :

១. ដំណាក់កាលមុនប្រតិបត្តិគំរោង (ការសាងសង់: ការរៀបចំការដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធ និងសាងសង់ រោងចក្រ

២. ដំណាក់កាលប្រតិបត្តិគំរោង: ការទាញយករ៉ែដែកពីក្នុងដី និងលើដី ហើយដឹកចូលរោងចក្រដើម្បីចំរាញ់យករ៉ែដែក។

៣. ដំណាក់កាលបញ្ចប់គំរោង: ជាដំណាក់កាលប្រគល់ទីតាំងដីសម្បទាននេះទៅឱ្យរាជរដ្ឋាភិបាល និងប្រជា-ពលរដ្ឋវិញ ព្រមទាំងស្តារបរិស្ថានដែលខូចខាតឱ្យមានលក្ខណៈល្អប្រសើរឡើងវិញ។

Draft

### ៧-៤-៤-១.កម្មវិធីត្រួតពិនិត្យបរិស្ថានក្នុងដំណាក់កាលមុនប្រតិបត្តិគំរោង

| គោលបំណង | សកម្មភាព និងភារកិច្ច | អ្នកទទួលខុសត្រូវ | ស្ថាប័នទទួលខុសត្រូវត្រួតពិនិត្យតាមដាន | ពេលវេលា/ភាពញឹកញាប់ |
|---|---|---|---|---|
| កាត់បន្ថយការប៉ះពាល់លើធនធានព្រៃឈើ និងសត្វព្រៃ | • ឈូសសំអាតគំរបព្រៃក្នុងទំហំសមល្មមតាមតំរូវការនៃការសាងសង់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងសំណង់ស៊ីវិលគំរោង | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/សប្ដាហ៍ |
| | • ឈូសសំអាតព្រៃជាដំណាក់ៗ ដោយត្រូវទុកផ្លូវឱ្យសត្វព្រៃរត់គេចខ្លួនចេញទៅតំបន់ផ្សេងៗ | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/03ខែ |
| | • ផ្សព្វផ្សាយ និងអប់រំណែនាំដល់បុគ្គលិក-កម្មករឱ្យយល់ដឹងពីសារៈសំខាន់នៃព្រៃឈើ និងសត្វព្រៃ ព្រមទាំងបទបញ្ជាដូចខាងក្រោម៖<br>- ហាមកាប់ដើមឈើសំរាប់ប្រើប្រាស់ជាអុសក្នុងការចំអិនអាហារ<br>- ហាមបរបាញ់ និងចាប់សត្វព្រៃ<br>- ហាមទិញសត្វព្រៃពីជននានា ជាពិសេសប្រជាពលរដ្ឋមូលដ្ឋាន<br>- ដាក់ពិន័យតឹងរឹង (ឧ. ព្រមាន ឬបញ្ឈប់ពីការងារ) ក្នុងករណីបុគ្គលិក-កម្មករណាមួយប្រព្រឹត្តិល្មើសនឹងបទបញ្ជាខាងលើ | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • មុនពេលចាប់ដំណើរការសាងសង់<br>• បន្ទាប់មក01ដង/03ខែ |
| | • ត្រួតពិនិត្យការឈូសសំអាតគំរបព្រៃ ដើម្បីធានាថាព្រៃទ្រនាប់តាមដងអូរមិនត្រូវបានឈូសឆាយ និងកាប់បំផ្លាញ | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/សប្ដាហ៍ |
| កាត់បន្ថយការប៉ះពាល់លើរចនាសម្ព័ន្ធ និង គុណភាពដី | • ជ្រើសរើសការដ្ឋានសាងសង់ទៅតាមផែនការមេ(ជំពូកទី03) | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • រាល់មុនពេលបោះការដ្ឋាន |
| | • ផ្សព្វផ្សាយ និងអប់រំណែនាំដល់បុគ្គលិក-កម្មករឱ្យយល់ដឹងអំពីគោលការណ៍បច្ចេកទេសនៃការទុកដាក់សំណល់គ្រប់ប្រភេទឱ្យមានសុវត្ថិភាព ឱ្យស្របទៅតាមអនុក្រឹត្យស្តីពីការបំពុលទឹក (1999) និងអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង (1999) | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • មុនពេលបើកការដ្ឋាន<br>• បន្ទាប់មក01ដង/03ខែ |
| កាត់បន្ថយការប៉ះពាល់លើប្រព័ន្ធផ្លូវទឹក និងគុណភាពទឹក | • ត្រួតពិនិត្យពីស្ថានភាពប្រព័ន្ធផ្លូវទឹក និងព្រៃឈើ (ប្រមាណ100ម. × 2) ទ្រនាប់តាមដងអូរ ដើម្បីធានានូវការមិនឈូសឆាយ មិនកាប់បំផ្លាញ ឬមិនធ្វើ | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/សប្ដាហ៍ |

| គោលបំណង | សកម្មភាព និងភារកិច្ច | អ្នកទទួលខុសត្រូវ | ស្ថាប័នទទួលខុសត្រូវត្រួតពិនិត្យតាមដាន | ពេលវេលា/ភាពញឹកញាប់ |
|---|---|---|---|---|
| | ឱ្យប៉ះពាល់ផ្សេងៗ | | | |
| | • ផ្សព្វផ្សាយ និងអប់រំណែនាំដល់បុគ្គលិក-កម្មករ ឱ្យយល់ដឹងអំពីគោលការណ៍បច្ចេកទេសនៃការទុកដាក់សំណល់គ្រប់ប្រភេទឱ្យមានសុវត្ថិភាព ឱ្យស្របទៅតាមអនុក្រឹត្យស្តីពីការបំពុលទឹក (1999) និងអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង (1999) | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • មុនពេលបើកការដ្ឋាន<br>• បន្ទាប់មក01ដង/03ខែ |
| កាត់បន្ថយការប៉ះពាល់លើគុណភាពខ្យល់ និងសំលេង-រំញ័រ | • ជ្រើសរើសគ្រឿងចក្រ និងយានយន្តបច្ចេកទេសថ្មី ដែលបញ្ចេញផ្សែង និងសំលេង-រំញ័រតិច | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • ពេលនាំចូលឧបករណ៍នានា |
| | • ត្រួតពិនិត្យ និងជួសជុលគ្រឿងចក្រ និងយានយន្ត (ឧ. ផ្លាស់ប្តូរប្រេងម៉ាស៊ីន) ដែលប្រើប្រាស់ សំរាប់ខ្សែសង្វាក់ផលិតកម្មឱ្យបានទៀងទាត់ ដើម្បីធានានូវកំរិតនៃការបញ្ចេញផ្សែង និង សំលេង-រំញ័រឱ្យនៅទាបក្រោមកំរិតស្តង់ដារ ដែលបានកំណត់ដោយអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង-រំញ័រ (2000) | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/03ខែ |
| កាត់បន្ថយការប៉ះពាល់នៃការប្រើប្រាស់ដីធ្លី | • សិក្សាស្រាវជ្រាវបន្ថែមអំពីទីតាំងដីស្រែ-ចំការរបស់ប្រជាពលរដ្ឋ និងសហការជាមួយអាជ្ញាធរដែនដី ដើម្បីធ្វើការដោះស្រាយផ្ទៃដីដែលប៉ះពាល់ឱ្យបានល្អបំផុត ដោយផ្អែកទៅលើលទ្ធផលនៃការពិភាក្សារវាងភាគីពាក់ព័ន្ធទាំងអស់ (គំរោង និងប្រជាពលរដ្ឋមូលដ្ឋាន និងអាជ្ញាធរដែនដី និងរាជរដ្ឋាភិបាល) | ក្រុមហ៊ុន និងអាជ្ញាធរដែនដី | MoE, MAFF, MIME, LA | • មុនពេលចាប់ផ្តើមដំណើរការសាងសង់ |
| | • តាមដាន និងដោះស្រាយការប៉ះពាល់ពាក់ព័ន្ធនឹងដីធ្លី ដោយសហការជាមួយប្រជាពលរដ្ឋមូលដ្ឋាន អាជ្ញាធរដែនដី និងរាជរដ្ឋាភិបាល | ក្រុមហ៊ុន និងអាជ្ញាធរដែនដី | MoE, MAFF, MIME, LA | • រាល់ពេលមានការប៉ះពាល់ |
| កាត់បន្ថយការប៉ះពាល់លើមុខរបរសហគមន៍មូលដ្ឋាន | • ផ្សព្វផ្សាយ និងណែនាំដល់បុគ្គលិក-កម្មករគំរោង ឱ្យអនុគ្រោះដល់ប្រជាពលរដ្ឋមូលដ្ឋានក្នុងការធ្វើស្រែ-ចំការ និងចូលប្រមូលអនុផលព្រៃឈើនៅក្នុង | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/03ខែ |

| គោលបំណង | សកម្មភាព និងភារកិច្ច | អ្នកទទួលខុសត្រូវ | ស្ថាប័នទទួលខុសត្រូវត្រួតពិនិត្យតាមដាន | ពេលវេលា/ភាពញឹកញាប់ |
|---|---|---|---|---|
| | ទីតាំងគំរោង | | | |
| កាត់បន្ថយការប៉ះពាល់លើប្រពៃណី-វប្បធម៌របស់ជនជាតិដើមភាគតិច | • ផ្សព្វផ្សាយ និងអប់រំណែនាំដល់បុគ្គលិក-កម្មករ ឱ្យចេះគោរព និងជួយថែរក្សាទំនៀមទំលាប់ ប្រពៃណី វប្បធម៌ និងជំនឿសាសនាជនជាតិដើមភាគតិច | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/06ខែ |
| កាត់បន្ថយការប៉ះពាល់ដល់សុខភាព និងសុវត្ថិភាពការងារ | • ផ្គត់ផ្គង់ទឹកស្អាតដល់បុគ្គលិក-កម្មករសំរាប់ប្រើប្រាស់ប្រចាំថ្ងៃ | ក្រុមហ៊ុន | MoE, MAFF, MIME, LA | • រៀងរាល់ថ្ងៃ |
| | • សាងសង់បង្គន់អនាម័យឱ្យបានគ្រប់គ្រាន់សំរាប់បុគ្គលិក-កម្មករប្រើប្រាស់ | ក្រុមហ៊ុន | MoE, MAFF, MIME, LA | • មុនពេលបើកការដ្ឋាន |
| | • ត្រួតពិនិត្យសុខភាព និងផ្តល់សេវាពិនិត្យ និងព្យាបាលជំងឺឱ្យបុគ្គលិក-កម្មករ ដោយឥតគិតថ្លៃ | ក្រុមហ៊ុន | MoE, MAFF, MIME, LA | • 01ដង/06ខែ និងរាល់ពេលចាំបាច់ |
| | • ផ្សព្វផ្សាយ និងអប់រំណែនាំដល់បុគ្គលិក-កម្មករ ឱ្យយល់ដឹងអំពីរបៀបសុខភាពអនាម័យ និងគោលការណ៍បច្ចេកទេសនៃការទុកដាក់សំណល់គ្រប់ប្រភេទឱ្យមានសុវត្ថិភាពឱ្យស្របទៅតាមអនុក្រឹត្យស្តីពីការបំពុលទឹក (1999) និងអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង (1999) | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • មុនពេលបើកការដ្ឋាន<br>• បន្ទាប់មក01ដង/03ខែ |

## ៧-៤-៤-២. កម្មវិធីត្រួតពិនិត្យបរិស្ថានក្នុងដំណាក់កាលប្រតិបត្តិគំរោង

| គោលបំណង | សកម្មភាព និងភារកិច្ច | អ្នកទទួលខុសត្រូវ | | ពេលវេលា/ភាពញឹកញាប់ |
|---|---|---|---|---|
| កាត់បន្ថយការប៉ះពាល់លើធនធានព្រៃឈើ និងសត្វព្រៃ | • ឈូសសំអាតគំរបព្រៃទៅតាមទំហំនៃតំបន់ និងការដ្ឋានជីកយកល្បាយអាចម៍រ៉ែ (12តំបន់) | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/សប្តាហ៍ |
| | • ឈូសសំអាតព្រៃជាដំណាក់ៗ ដោយត្រូវទុកផ្លូវឱ្យសត្វព្រៃគេចខ្លួនចេញទៅតំបន់ផ្សេងៗ | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/03ខែ |
| | • ផ្សព្វផ្សាយ និងអប់រំណែនាំដល់បុគ្គលិក-កម្មករ ឱ្យយល់ដឹងពីសារៈសំខាន់នៃព្រៃឈើ និងសត្វព្រៃ ព្រមទាំងដាក់បទបញ្ជាដូចខាងក្រោម: | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • មុនពេលចាប់ដំណើរការ<br>• បន្ទាប់មក01ដង/03ខែ |

| គោលបំណង | សកម្មភាព និងភារកិច្ច | អ្នកទទួលខុសត្រូវ | | ពេលវេលា/ភាពញឹកញាប់ |
|---|---|---|---|---|
| | - ហាមកាប់ដើមឈើសំរាប់ប្រើប្រាស់ជាអុសក្នុងការចំអិនអាហារ<br>- ហាមបរបាញ់ និងចាប់សត្វព្រៃ<br>- ហាមទិញសត្វព្រៃពីជននានា ជាពិសេសប្រជាជនមូលដ្ឋាន<br>- ដាក់ពិន័យតឹងរឹង(ឧ. ព្រមាន ឬបញ្ឈប់ពីការងារ) ក្នុងករណីបុគ្គលិក-កម្មករណាមួយ ប្រព្រឹត្តិល្មើសនឹងបទបញ្ជាខាងលើ | | | |
| | • ត្រួតពិនិត្យការឈូសសំអាតគំរបព្រៃ ដើម្បីធានាថាព្រៃទ្រនាប់តាមដងអូរ (ផ្ទៃដីសរុប400ហ.ត.) មិនត្រូវបានឈូសឆាយ និងកាប់បំផ្លាញ | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/សប្តាហ៍ |
| កាត់បន្ថយការប៉ះពាល់ដល់រចនា-សម្ព័ន្ធ និងគុណភាពដី | • ឈូសបើកគំរបព្រៃទៅតាមលទ្ធភាពនៃគំរោងធ្វើអាជីវកម្មនៅតំបន់ ឬដំណាក់កាល ឬឆ្នាំនីមួយៗ ដោយមិនត្រូវបន្សល់ទុកនូវផ្ទៃដីដែលឈូសសំអាតហើយឱ្យនៅទំនេរ ឬពន្យាពេលជីកយកគល្លាយអាចម៍រ៉ែ | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • រាល់មុនពេលបោះការដ្ឋាន |
| | • គ្រប់គ្រងការទុកដាក់ដីដែលបានជីកយកចេញឱ្យបានត្រឹមត្រូវ | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • រាល់ពេលមានការជីកដី |
| | • ផ្សព្វផ្សាយ និងអប់រំណែនាំដល់បុគ្គលិក-កម្មករ ឱ្យយល់ដឹងអំពីគោលការណ៍បច្ចេកទេសនៃការគ្រប់គ្រង និងទុកដាក់សំណល់ និងសារធាតុគីមីផ្សេងៗឱ្យបានត្រឹមត្រូវទៅតាមអនុក្រឹត្យស្តីពីការបំពុលទឹក (1999) និងអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង (1999) | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/03ខែ |
| កាត់បន្ថយការប៉ះពាល់ដល់ប្រព័ន្ធផ្លូវទឹក និងគុណភាពទឹក | • ត្រួតពិនិត្យពីស្ថានភាពប្រព័ន្ធផ្លូវទឹក និងព្រៃឈើ (ប្រមាណ100ម.×2) ទ្រនាប់តាមដងអូរ ដើម្បីធានានូវការមិនឈូសឆាយ មិនកាប់បំផ្លាញ ឬមិនធ្វើឱ្យប៉ះពាល់ផ្សេងៗ | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/03ខែ |
| | • ផ្សព្វផ្សាយ និងអប់រំណែនាំដល់បុគ្គលិក-កម្មករ ឱ្យយល់ដឹងអំពីគោលការណ៍បច្ចេកទេសនៃការគ្រប់គ្រង និងទុកដាក់សំណល់ និងសារធាតុគីមីផ្សេងៗឱ្យបានត្រឹមត្រូវទៅតាមអនុក្រឹត្យស្តីពីការបំពុលទឹក (1999) និងអនុក្រឹត្យ | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/03ខែ |

| គោលបំណង | សកម្មភាព និងភារកិច្ច | អ្នកទទួលខុសត្រូវ | | ពេលវេលា/ភាពញឹកញាប់ |
|---|---|---|---|---|
| | ស្តីពីការគ្រប់គ្រងសំណល់រឹង (1999) | | | |
| | • ត្រួតពិនិត្យប្រព័ន្ធលូបង្ហូរទឹកឱ្យបានទៀងទាត់តាមលក្ខណៈបច្ចេកទេស | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/01ខែ |
| | • ត្រួតពិនិត្យ និងវិភាគគុណភាពទឹកតាមប្រព័ន្ធផ្លូវទឹកអូរ និងទឹកអណ្តូងច្រប់ (ជំពូកទី04) | ក្រុមហ៊ុន | MoE, MAFF, MIME, LA | • 01ដង/06ខែ |
| កាត់បន្ថយការប៉ះពាល់ដល់គុណភាពខ្យល់ និងសំលេង-រំញ័រ | • ត្រួតពិនិត្យ និងជួសជុលគ្រឿងចក្រ និងយានយន្ត (ឧ. ផ្លាស់ប្តូរប្រេងម៉ាស៊ីន) និងបន្ទះជ័រកៅស៊ូទន់-រឹង ដែលប្រើប្រាស់សំរាប់ខ្សែសង្វាក់អាជីវកម្មឱ្យបានទៀងទាត់ ដើម្បីធានានូវកំរិតនៃការបញ្ចេញផ្សែង និងសំលេង-រំញ័រឱ្យនៅទាបក្រោមកំរិតស្តង់ដារដែលបានកំណត់ដោយអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង-រំញ័រ (2000) | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/03ខែ |
| កាត់បន្ថយការប៉ះពាល់នៃការប្រើប្រាស់ដីធ្លីដែលនៅសេសសល់ ឬកើតឡើងដោយចៃដន្យ | • តាមដាន និងដោះស្រាយរាល់ការប៉ះពាល់ពាក់ព័ន្ធនឹងដីធ្លី ដោយសហការជាមួយប្រជាពលរដ្ឋមូលដ្ឋាន អាជ្ញាធរដែនដី និងរាជរដ្ឋាភិបាល | ក្រុមហ៊ុន និងអាជ្ញាធរដែនដី | MoE, MAFF, MIME, LA | • រាល់ពេលមានការប៉ះពាល់ដីធ្លី |
| កាត់បន្ថយការប៉ះពាល់ដល់មុខរបរសហគមន៍មូលដ្ឋាន | • ផ្តល់អាទិភាពទទួលបានការងារធ្វើនៅក្នុងគំរោងដល់ប្រជាពលរដ្ឋមូលដ្ឋាន | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • រាល់ពេលមានតំរូវការកំលាំងពលកម្ម |
| | • ផ្សព្វផ្សាយ និងណែនាំដល់បុគ្គលិក-កម្មករក្រុមហ៊ុន ឱ្យអនុគ្រោះដល់ប្រជាពលរដ្ឋមូលដ្ឋានក្នុងការចូលប្រមូលអនុផលព្រៃឈើនៅក្នុងទីតាំងគំរោង | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/06ខែ |
| កាត់បន្ថយការប៉ះពាល់ដល់ប្រពៃណី-វប្បធម៌របស់ជនជាតិដើមភាគតិច | • ផ្សព្វផ្សាយ និងអប់រំណែនាំដល់បុគ្គលិក-កម្មករ ឱ្យចេះគោរព និងជួយថែរក្សាទំនៀមទំលាប់ ប្រពៃណី វប្បធម៌ និងជំនឿសាសនាជនជាតិដើមភាគតិច | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/06ខែ |
| កាត់បន្ថយការប៉ះពាល់ដល់សុខភាព និង សុវត្ថិភាពការងារ | • ផ្គត់ផ្គង់ទឹកស្អាតដល់បុគ្គលិក-កម្មករសំរាប់ប្រើប្រាស់ប្រចាំថ្ងៃ | ក្រុមហ៊ុន | MoE, MAFF, MIME, LA | • រៀងរាល់ថ្ងៃ |
| | • ត្រួតពិនិត្យសុខភាព និងផ្តល់សេវាពិនិត្យ និងព្យាបាលជំងឺឱ្យបុគ្គលិក-កម្មករដោយឥតគិតថ្លៃ | ក្រុមហ៊ុន | MoE, MAFF, MIME, LA | • 01ដង/06ខែ និងរាល់ពេលចាំបាច់ |

| គោលបំណង | សកម្មភាព និងភារកិច្ច | អ្នកទទួលខុសត្រូវ | | ពេលវេលា/ភាពញឹកញាប់ |
|---|---|---|---|---|
| | • ត្រួតពិនិត្យ និងសាងសង់បង្គន់អនាម័យបន្ថែមឱ្យបានគ្រប់គ្រាន់សំរាប់បុគ្គលិក-កម្មករប្រើប្រាស់ | ក្រុមហ៊ុន | MoE, MAFF, MIME, LA | • មុនពេលប្រតិបត្តិគំរោង |
| | • រៀបចំកម្មវិធីធ្វើអនាម័យបរិស្ថាននៅក្នុងបរិវេណទីស្នាក់ការ/ជំរុំស្នាក់នៅ | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/ខែ |
| | • ផ្សព្វផ្សាយ និងអប់រំណែនាំដល់បុគ្គលិក-កម្មករ ឱ្យយល់ដឹងអំពីរបៀបសុខភាពអនាម័យ និងគោលការណ៍បច្ចេកទេសនៃការទុកដាក់សំណល់គ្រប់ប្រភេទឱ្យមានសុវត្ថិភាពឱ្យស្របទៅតាមអនុក្រឹត្យស្តីពីការបំពុលទឹក (1999) និងអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង (1999) | ក្រុមហ៊ុន និងអ្នកម៉ៅការ | MoE, MAFF, MIME, LA | • 01ដង/03ខែ |

សំគាល់:

- MoE: ក្រសួងបរិស្ថាន រួមមាន នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុការវាយតំលៃហេតុប៉ះពាល់បរិស្ថាន នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន មន្ទីរបរិស្ថានខេត្ត
- MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមមាន រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល មន្ទីរកសិកម្មខេត្ត-ក្រុង
- MIME: ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រួមមាន នាយកដ្ឋានពាក់ព័ន្ធទទួលបន្ទុកធនធានរ៉ែ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត
- LA: អាជ្ញាធរដែនដី រួមមាន ថ្នាក់ខេត្ត ក្រុង ស្រុក ឃុំ ភូមិ

### ៧.៤-៤-៣. កម្មវិធីត្រួតពិនិត្យបរិស្ថានក្នុងដំណាក់កាលបញ្ចប់គំរោង

ក្រុមហ៊ុនគ្រោងនឹងធ្វើអាជីវកម្មរយៈពេល09,50ឆ្នាំ (១១៤ខែ) តាមការអនុញ្ញាតរបស់រាជរដ្ឋាភិបាល ហើយបន្ទាប់មកក្រុមហ៊ុននឹងប្រគល់ទីតាំងនេះជូនរាជរដ្ឋាភិបាលវិញទាំងស្រុង ដើម្បីបន្តសកម្មភាពគំរោង ឬធ្វើការអភិវឌ្ឍន៍លើគំរោងថ្មីផ្សេងទៀត ឬប្រើប្រាស់ក្នុងគោលបំណងដូចមុនពេលផ្តល់សម្បទាន ប្រសិនបើមិនមានផែនការអភិវឌ្ឍន៍អ្វីបន្តទៀតនោះទេ។

ក្នុងករណីដែលត្រូវបន្តសកម្មភាពគំរោង ក្រុមហ៊ុន ឬអ្នកទទួលខុសត្រូវបន្ត ត្រូវបន្តគោរព និងអនុវត្តន៍តាមរាល់សកម្មភាពត្រួតពិនិត្យ និងអង្កេតតាមដានបរិស្ថាន ក៏ដូចជារបាយការណ៍នៃការអនុវត្តន៍រហូតដល់សកម្មភាពបិទគំរោង និងការស្តារបរិស្ថានឡើងវិញត្រូវបានបញ្ចប់ជាស្ថាពរ។ ក្នុងករណីដែលត្រូវបិទគំរោង ក្រុមហ៊ុន Hoang Anh Rattanakiri Co., Ltd. នឹងរៀបចំផែនការបិទគំរោង និងស្តារបរិស្ថានដែលបានខូចខាត និងសេសសល់ឱ្យមានល្អប្រសើរឡើងវិញ។

ទោះបីជាមានផែនការគ្រប់គ្រងបរិស្ថានដូចរៀបរាប់ខាងលើ ការប៉ះពាល់បរិស្ថាន-សង្គមអវិជ្ជមាននៅតែមានសេសសល់ ហើយអ្នកដែលទទួលរងនូវការប៉ះពាល់ទាំងនេះ គឺប្រជាពលរដ្ឋមូលដ្ឋាន។ ដើម្បីប៉ះប៉ូវនូវការប៉ះពាល់ដែលនៅសេសសល់នេះ ក្រុមហ៊ុននឹងបង្កើតនូវមូលនិធិបរិស្ថាន និងមូលនិធិសង្គម ព្រមទាំងផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋមួយចំនួនឱ្យទទួលបានឱកាសការងារ និងពិនិត្យលទ្ធភាពដើម្បីចូលរួមជួយអភិវឌ្ឍន៍ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជនបទបន្ថែមនៅក្នុងតំបន់គំរោង (ឧ. ផ្លូវថ្នល់ បណ្តាញចរន្តអគ្គិសនី និងទឹកស្អាតជាដើម) នៅពេលក្រុមហ៊ុនចាប់ផ្តើមដំណើរការអាជីវកម្ម។

## ៧.៥. ផែនការថវិកាសំរាប់អនុវត្តផែនការគ្រប់គ្រងបរិស្ថាន

ការចូលរួមអភិវឌ្ឍន៍សហគមន៍មូលដ្ឋានរបស់ក្រុមហ៊ុន គឺមានសារៈសំខាន់ណាស់ក្នុងការជួយឱ្យដំណើរការធ្វើអាជីវកម្មរ៉ែដែករបស់ខ្លួន និងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់មានភាពប្រសើរឡើង និងអាចទទួលយកបានសំរាប់ភាគីទាំងអស់។ តាមរយៈការសិក្សា និងការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន ក៏ដូចជាជាមួយស្ថាប័នជំនាញពាក់ព័ន្ធផ្សេងៗ ក្រុមហ៊ុនបានរៀបចំឡើងនូវមូលនិធិបរិស្ថានសំរាប់ការស្តារបរិស្ថាន និងព្រៃឈើឡើងវិញដែលមានថវិកាសរុបចំនួន**១.៨០៧.៩៤០ ដុល្លាអាមេរិក** និងមូលនិធិសង្គមសំរាប់យកមកអភិវឌ្ឍន៍ភូមិ-ឃុំដែលពាក់ព័ន្ធនឹងទីតាំងគំរោងដោយចំណាយថវិកាអស់ចំនួន ៨៩២.000 ដុល្លាអាមេរិក សំរាប់រយៈពេល**១០ឆ្នាំ** ដូចមានបញ្ជាក់ដូចខាងក្រោម៖

Draft

### ៧.៥.១ មូលនិធិបរិស្ថាន

ម្ចាស់គំរោងនឹងមានផែនការចំណាយថវិកាសំរាប់ការងារស្តារបរិស្ថាន និងដាំដើមឈើឡើងវិញក្នុងរយៈពេល ១០ ឆ្នាំ មានចំនួន **១.៨០៧.៩៤០ ដុល្លារអាមេរិក ស្មើនឹង ១៨.០៧៩៤ ដុល្លារអាមេរិក/ឆ្នាំ** ( របាយការណ៍របស់ក្រុមហ៊ុន ២០១១) ។

### ៧.៥.២ មូលនិធិសង្គម

ម្ចាស់គំរោងមានផែនការផ្តល់មូលនិធិសង្គមសំរាប់ការអភិវឌ្ឍន៍ភូមិ-ឃុំ និងបណ្តុះបណ្តាលជំនាញការចិញ្ចឹមសត្វស្រុក ចិញ្ចឹមត្រី ដាំដំណាំកៅស៊ូ ដាំដំឡូងមី និងការសាងសង់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនានាដូចមានបញ្ជាក់ដូចខាងក្រោម:

ក្រុមហ៊ុនផ្តល់វគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេសចិញ្ចឹមសត្វស្រុកដល់ប្រជាពលរដ្ឋមូលដ្ឋាន មានរយៈពេល ០៧ឆ្នាំ ហើយនឹងអនុវត្តន៏សំរាប់ប្រជាពលរដ្ឋគោលដៅសរុបចំនួនប្រមាណ ២.១០០គ្រួសារ ( ៣០០គ្រួសារ/ឆ្នាំ) ។

ក្រុមហ៊ុនផ្តល់វគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេសចិញ្ចឹមត្រី (ឬជួយផ្តល់កូនត្រី) ដល់ប្រជាពលរដ្ឋមូលដ្ឋានជាដើម ដែលមានរយៈពេល ០៧ឆ្នាំ ហើយនឹងអនុវត្តន៏សំរាប់ប្រជាពលរដ្ឋគោលដៅសរុបចំនួនប្រមាណ ២.១០០គ្រួសារ ដោយមានចំនួន ៣០០គ្រួសារ/ឆ្នាំ ។

ក្រុមហ៊ុនបាន និងធ្វើការស្តារ និងជួសជុលផ្លូវទាំងនេះឡើងវិញក្នុងរយៈពេល ១០ ឆ្នាំ ដោយគ្រោងនឹងចំណាយថវិកាសរុបចំនួន ៥៥០.០០០ដុល្លាអាមេរិក ស្មើនឹង ៥៥.០០០ដុល្លាអាមេរិក/ឆ្នាំ ។ ជាមួយគ្នានេះដែរ ក្រុមហ៊ុនក៏គ្រោងនឹងសាងសង់ផ្លូវថ្មីមួយចំនួនទៀតនៅក្នុងទីតាំងគំរោង ដោយផ្លូវទាំងនេះក៏អាចប្រើប្រាស់សំរាប់ការធ្វើដំណើរ និងការដឹកជញ្ជូនរបស់សហគមន៏មូលដ្ឋានផងដែរ ។

ក្រុមហ៊ុននឹងផ្តល់វគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេសដាំដំណាំកៅស៊ូទៅដល់ប្រជាពលរដ្ឋមូលដ្ឋាន ក្នុងរយៈពេល ០៧ឆ្នាំ ដោយគ្រោងនឹងចំណាយថវិកាសរុបចំនួន ៦៣.០០០ដុល្លាអាមេរិក ហើយក្នុង០១ឆ្នាំនឹងត្រូវចំណាយថវិកាចំនួន ៩.០០០ដុល្លាអាមេរិក សំរាប់ប្រជាពលរដ្ឋគោលដៅសរុបចំនួន ២.១០០គ្រួសារ គឺ៣០០គ្រួសារ/ឆ្នាំ ។ ជាមួយគ្នានេះដែរ ក្រុមហ៊ុនក៏គ្រោងនឹងជំរុញឱ្យប្រជាពលរដ្ឋមូលដ្ឋានចូលរួមធ្វើការដាំកៅស៊ូជាលក្ខណៈកិច្ចសន្យា ជាមួយក្រុមហ៊ុនផ្សេងទៀតដែលជាសាខារបស់ក្រុមហ៊ុនមេ Hoang Anhy Gia Lai ដែលធ្វើការអភិវឌ្ឍន៏វិស័យដាំដំណាំកៅស៊ូនេះ ។

ក្រុមហ៊ុននឹងផ្តល់វគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេសដាំដំណាំដំឡូងមីទៅដល់ប្រជាពលរដ្ឋមូលដ្ឋាន ក្នុងរយៈពេល ០៧ឆ្នាំ ដោយគ្រោងនឹងចំណាយថវិកាសរុបចំនួន ៦៣.០០០ដុល្លាអាមេរិក ស្មើនឹង ៩.០០០ដុល្លាអាមេរិក/ឆ្នាំ សំរាប់ប្រជាពលរដ្ឋគោលដៅសរុបចំនួន ២.១០០គ្រួសារ ( ៣០០គ្រួសារ/ឆ្នាំ) ។

ក្រុមហ៊ុននឹងជួយស្វះស្វែងរកអ្នកជំនាញបច្ចេកទេសដាំដុះទាំងនេះ ក្នុងន័យដើម្បីជួយលើកតំកើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងដើម្បីផ្តល់សេវាកម្មផ្នែកទីប្រឹក្សា-ពិគ្រោះយោបល់អំពីបច្ចេកទេសនៃការដាំដំណាំផ្សេងៗ

Draft

ជូនប្រជាពលរដ្ឋមូលដ្ឋានបន្ថែមពីលើដំណាំកៅស៊ូ និងដំឡូងមី ។ ការផ្តល់សេវាកម្មនេះមានរយៈពេល ១០ឆ្នាំ និងចំណាយថវិកាសរុបចំនួន ៩០.០០០ដុល្លារអាមេរិក ស្មើនឹង ៩.០០០ដុល្លារអាមេរិក/ឆ្នាំ ។

លើសពីនេះទៀត បន្ទាប់ពីក្រុមហ៊ុនទទួលបានការអនុញ្ញាតឱ្យធ្វើអាជីវកម្មរ៉ែដែក ក្រុមហ៊ុននឹងរៀបចំតំឡើង និងតភ្ជាប់បណ្តាញចរន្តអគ្គិសនីមកក្នុងទីតាំងគំរោង ដោយក្រុមហ៊ុននឹងធ្វើការចែកចាយចរន្តអគ្គិសនីនេះទៅដល់ប្រជា-ពលរដ្ឋមូលដ្ឋានដែលទទួលរងការប៉ះពាល់នេះឱ្យបានប្រើប្រាស់ដែរ ។

ចំណែកប្រជាពលរដ្ឋដែលរងការប៉ះពាល់ផ្ទាល់ ក្រុមហ៊ុននឹងធ្វើការរៀបចំសាងសង់ផ្ទះឈើជូនប្រជាពលរដ្ឋដែលទទួលរងការប៉ះពាល់ចំនួន ១០០ខ្នង/ភូមិ ដែលក្នុងនោះផ្ទះនីមួយៗធ្វើពីឈើប្រក់សង្កសី ឬក្បឿងក្នុងទំហំ ៦០ម$^{២}$ ។ ដើម្បីឱ្យការងារសាងសង់នេះប្រព្រឹត្តទៅបានល្អ និងចំណាយពេលវេលាតិច ក្រុមហ៊ុននឹងស្នើសុំ ឬស្នើទិញឈើនៅក្នុងទីតាំងគំរោងនេះពីរាជរដ្ឋាភិបាល ។

Draft

### តារាង 33: ផែនការថវិកាសំរាប់អនុវត្តផែនការគ្រប់គ្រងបរិស្ថាន

| ល.រ. | សកម្មភាព | វដ្តផែនការ និងការចំណាយ (US$) | | | | | | | | | | ចំណាយ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឆ្នាំទី01 | ឆ្នាំទី02 | ឆ្នាំទី03 | ឆ្នាំទី04 | ឆ្នាំទី05 | ឆ្នាំទី06 | ឆ្នាំទី07 | ឆ្នាំទី08 | ឆ្នាំទី09 | ឆ្នាំទី10 | (US$/ឯកតា) | (US$) |
| | **មូលនិធិបរិស្ថាន** | 180,794 | 180,794 | 180,794 | 180,794 | 180,794 | 180,794 | 18,0794 | 180,794 | 180,794 | 180,794 | | 1,807,940 |
| | **មូលនិធិសង្គម** | | | | | | | | | | | | |
| 1 | បណ្តុះបណ្តាលផ្នែកបច្ចេកទេសចិញ្ចឹមសត្វស្រុក | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | — | — | — | (30/គ្រួ.) | 63,000 |
| 2 | បណ្តុះបណ្តាលផ្នែកបច្ចេកទេសចិញ្ចឹមត្រី (ឬផ្តល់កូនត្រី) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | — | — | — | (30/គ្រួ.) | 63,000 |
| 3 | បណ្តុះបណ្តាលផ្នែកបច្ចេកទេសដាំដំណាំកៅស៊ូ | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | — | — | — | (30/គ្រួ.) | 63,000 |
| 4 | បណ្តុះបណ្តាលផ្នែកបច្ចេកទេសដាំដំណាំឈើឡុងមី | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | — | — | — | (30/គ្រួ.) | 63,000 |
| 5 | ផ្តល់សេវាកម្មទីប្រឹក្សាសំរាប់ការដាំដុះដំណាំផ្សេងៗ | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | 9,000<br>(300គ្រួ.) | (30/គ្រួ.) | 90,000 |
| 6 | ស្ពាន និងជួសជុលផ្លូវលំ | 55,000 | 55,000 | 55,000 | 55,000 | 55,000 | 55,000 | 55,000 | 55,000 | 55,000 | 55,000 | — | 500,000 |
| 7* | ការរៀបចំបណ្តាញចរន្តអគ្គិសនី | — | — | — | — | — | — | — | — | — | — | — | — |
| 8* | [illegible]ការរៀបចំសាងសង់[illegible] | — | — | — | — | — | — | — | — | — | — | — | — |
| | **សរុប-ក (US$)** | 100,000 | 100,000 | 100,000 | 100,000 | 100,000 | 100,000 | 100,000 | 64,000 | 64,000 | 64,000 | — | 892,000 |

*មិនទាន់អាចកំណត់បានច្បាស់លាស់

**គួរកត់សំគាល់:** ដោយហេតុថាវិស័យអប់រំ និងសុខាភិបាល គឺវិស័យដែលត្រូវការលក្ខណៈបច្ចេកទេស និងស្តង់ដាខ្ពស់ដែលក្រុមហ៊ុនពុំមាន ដូច្នេះក្រុមហ៊ុនបានកែប្រែពីការសាងសង់សាលារៀន ឬប៉ុស្តិ៍សុខភាព ទៅជាផ្តល់សេវាកម្ម និងការបណ្តុះបណ្តាលផ្នែកបច្ចេកទេសចិញ្ចឹមសត្វ និងដាំដំណាំផ្សេងៗ ដើម្បីជួយកែលំអការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋមូលដ្ឋាន ក៏ដូចជាជួយអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមផងដែរ។